**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ធ៧៣....០១៩..២០៣...ស.ជ.ល

ថ្ងៃអង្គារ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង
## ពិធីផ្សព្វផ្សាយសៀវភៅស្តីពី ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០១៨

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងរៀបចំពិធីផ្សព្វផ្សាយសៀវភៅស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ នៅថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ខាងមុខ នៅសាលប្រជុំ ផ្សារទំនើប អ៊ីអនមល សែនសុខ ស៊ីធី ចាប់ពីម៉ោង២:០០ ដល់ ៣:៣៥ នាទី។ ពិធីនេះនឹងមានការចូលរួមពីតំណាងមកពីក្រសួង-ស្ថាប័ន គ្រឹះស្ថានហិរញ្ញវត្ថុ ស្ថាប័នអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍នានា។

ពិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយលទ្ធផលវិភាគស្តីពី ស្ថិរភាពហិរញ្ញវត្ថុកម្ពុជាប្រចាំឆ្នាំ២០១៨ និងប្រមូលធាតុចូលពីភាគីពាក់ព័ន្ធនានា ដើម្បីធ្វើឱ្យការវិភាគកាន់តែមានភាពគ្រប់ជ្រុងជ្រោយ សំដៅរួមចំណែកផ្តល់ជាឯកសារមួយសម្រាប់សាធារណជនសិក្សាស្វែងយល់ពីវិស័យហិរញ្ញវត្ថុ និងជាឯកសារជំនួយដល់ការរៀបចំគោលនយោបាយនានារបស់វិស័យសាធារណៈ និងឯកជន។

ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ការិយាល័យទំនាក់ទំនងរបស់ធនាគារជាតិនៃកម្ពុជាតាមរយៈអ៊ីម៉ែល nbccommunication@nbc.org.kh ឬលេខទូរសព្ទ ០២៣ ៩៨០ ១៩៦។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរសព្ទ៖ ០២៣ ៩៨០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh